# វិធានការជីវសុវត្ថិភាព ដើម្បីបង្ការជំងឺផ្តាសាយបក្សី និង ជំងឺបក្សីដទៃទៀត

## សៀវភៅណែនាំ សំរាប់កសិករចិញ្ចឹមបក្សីជាលក្ខណៈគ្រួសារ



USAID
FROM THE AMERICAN PEOPLE

COOPERATION
KINGDOM OF CAMBODIA
FEDERAL REPUBLIC OF GERMANY

**បោះពុម្ពដោយៈ**

វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល

នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**គាំទ្របច្ចេកទេសដោយៈ**

អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ

**អាសយដ្ឋានៈ**

ផ្លូវសទ្បា សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ

រាជធានីភ្នំពេញ ប្រទេសកម្ពុជា

**ប្រព័ន្ធព័ត៌មានទាន់ហេតុការណ៍សម្រាប់សុខភាពសត្វៈ**

០១២ ៨៣៣ ៧៩៥

០១២ ២១៤ ៩៧០

**ខែ មិថុនា ឆ្នាំ ២០០៩**

រូបថតនៅលើគំរបសៀវភៅៈ ប្រើអង្រុតក្នុងការចិញ្ចឹមបក្សីជាលក្ខណៈគ្រួសារ

## សេចក្តីថ្លែងអំណរគុណ

នាយកដ្ឋានផលិតកម្ម និងបសុព្យាបាលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិប្រចាំប្រទេសកម្ពុជា សូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅដល់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ និងរដ្ឋាភិបាលអាល្លឺម៉ង់ ដែលបានផ្តល់មូលនិធិសម្រាប់ចងក្រង និងបោះពុម្ពសៀវភៅនេះឡើង។

# តារាងមាតិកា


I. សេចក្តីផ្តើម ---------- ៥

II. ជំងឺផ្តាសាយបក្សី (AI) ---------- ៥

តើវីរុសនេះរីករាលដាលយ៉ាងដូចម្តេច? ---------- ៥

តើជំងឺបក្សីឆ្លងរាលដាលដោយរបៀបណា? ---------- ៦

III. ដូច្នេះ តើខ្ញុំត្រូវការជីវសុវត្ថិភាពក្នុងកំរិតណា? ---------- ១០

ក. ការដាក់អោយនៅដោយឡែក - ការពារបក្សីរបស់អ្នក ---------- ១០

ខ. ការត្រួតពិនិត្យចរាចរ ---------- ១១

គ. អនាម័យ ---------- ១២

IV. ឈ្មួញកណ្តាល និង អ្នកលក់បក្សីរស់ក្នុងផ្សារ ---------- ១៤

V. ឧបសម្ព័ន្ធទី ១ ---------- ១៩

## I- សេចក្តីផ្តើម

ជីវសុវត្ថិភាព គឺជាពាក្យដែលគេប្រើជារួម ដើម្បីរៀបរាប់ពីវិធានការផ្សេងៗ ដែលត្រូវអនុវត្តដោយអ្នកចិញ្ចឹមបក្សី (កសិដ្ឋានពាក់កណ្តាលឧស្សាហកម្ម និង ឧស្សាហកម្ម) អ្នកទិញលក់បក្សី និងផលិតផលដើមកំណើតពីបក្សី និង អ្នកដឹកជញ្ជូនបក្សី ដើម្បីបង្ការ និង បញ្ចៀស មិនអោយមានគ្រោះថ្នាក់ ដោយសារជំងឺឆ្លងនានា។ វិធានការជីវសុវត្ថិភាពទាំងនេះ ក៏ត្រូវបានគេអនុវត្ត ដើម្បីការពារមិនអោយមានការរាលដាលជំងឺ ពីកន្លែងមួយ ទៅកន្លែងមួយទៀតផងដែរ។

ជំងឺដែលកើតលើបក្សី មានផលប៉ះពាល់យ៉ាងខ្លាំងក្លា មកលើស្ថានភាពសង្គម សេដ្ឋកិច្ចជាតិរបស់ប្រទេស ដូច្នេះជាការសំខាន់ណាស់ ដែលត្រូវមានការអនុវត្តវិធានការជីវសុវត្ថិភាពក្នុងកំរិតមួយ ដើម្បីការពារទាំងសុខភាពសត្វ ផង និង ទាំងសុខភាពមនុស្សផង។

## II- ជំងឺផ្តាសាយបក្សី (AI)

AI (អក្សរកាត់ ដែលមានន័យថាជំងឺផ្តាសាយបក្សី) ត្រូវបានគេហៅជាញឹកញាប់ថា Bird Flu (ជំងឺផ្តាសាយបក្សី)។ ជំងឺនេះ ជាជំងឺដែលមានលក្ខណៈជាប្រព័ន្ធ អាចធ្វើអោយស្លាប់ក្នុងកំរិតមួយខ្ពស់ និង បង្កឡើងដោយវីរុស។ ជំងឺនេះអាចរីករាលដាលយ៉ាងឆាប់រហ័ស នៅក្នុងហ្វូងបក្សី ធ្វើអោយបក្សីងាប់ក្នុងកំរិតខ្ពស់ និង មានគ្រោះថ្នាក់ដល់សុខភាពរបស់មនុស្ស។ ជំងឺផ្តាសាយបក្សីដែលមានកំរិតចំលងខ្ពស់ (HPAI) គឺជាប្រភេទជំងឺផ្តាសាយបក្សី ដែលកំពុងរីករាលដាលនៅតាមប្រទេសមួយចំនួន រួមទាំងប្រទេសកម្ពុជាផងដែរ។ គ្រប់ប្រភេទបក្សីទាំងអស់ (មាន់ ទា មាន់បារាំង ក្រួច ក្ងាក និង បក្សីព្រៃដទៃទៀត ជាពិសេស បក្សីទឹកព្រៃ) សុទ្ធតែងាយឆ្លងវីរុសផ្តាសាយបក្សី (AIV)។ ទាអាចផ្ទុកវីរុសផ្តាសាយបក្សី ដោយមិនបញ្ចេញរោគសញ្ញាជំងឺឡើយ ហើយត្រូវបានគេចាត់ទុកថាជាឃ្លាំងស្តុកវីរុសផ្តាសាយបក្សីដ៏សំខាន់ ដើម្បីចំលងទៅកាន់បក្សីស្រុក។

### តើវីរុសនេះរីករាលដាលយ៉ាងដូចម្តេច?

១. ការប៉ះពាល់ជាមួយនឹងបក្សីឈឺ និង ផលិតផលមានដើមកំណើតពីបក្សី ដែលមានជាប់មេរោគ
២. ការដឹកជញ្ជូនបក្សីឈឺ និង ផលិតផលមានដើមកំណើតពីបក្សី ដែលមានជាប់មេរោគ ពីកន្លែងមួយទៅកន្លែងមួយទៀត
៣. ការប្រើប្រាស់យានជំនិះ និង ឧបករណ៍ ឬ សម្ភារៈប្រើប្រាស់ ដែលមានជាប់មេរោគ
៤. ការប្រមូលបក្សីពីប្រភពមិនស្គាល់ តាមកន្លែងផ្សេងៗគ្នា
៥. ការប្រើប្រាស់ឧបករណ៍ និង សម្ភារៈដទៃទៀតដែលមានជាប់មេរោគ ពីទ្រុង ឬ កន្លែងដទៃទៀត
៦. ការចូលរបស់មនុស្សប្លែកមុខ មកក្នុងទីធ្លា ជិតនឹងបក្សី

៧. ការចិញ្ចឹមបក្សីពាសវាលពាសកាល និង គ្មានដាក់ទ្រុង ឬ ធ្វើរបង ដែលធ្វើអោយបក្សីប៉ះពាល់ជាមួយនឹង បរិស្ថានដែលមានមេរោគ

៨. ផ្សារ និង កន្លែងសំលាប់ ដែលមិនមានការសំអាត និង ការសំលាប់មេរោគអោយបានស្អាតល្អ

៩. វីរុសក៏អាចចំលងតាមរយៈមនុស្ស កណ្តុរ សត្វល្អិត រុយ បក្សីហើរដោយសេរី ដូចជា ចាប និង រំពេ ។ល។

១០. ចំណី និង ទឹកមកពីប្រភពដែលមិនស្គាល់

១១. ការដាក់បក្សីប្រភេទផ្សេងៗគ្នា អោយនៅលាយឡំគ្នា

កសិដ្ឋានទី ១

## តើជំងឺបក្សីឆ្លងរាលដាល ដោយរបៀបណា?







ការដឹកជញ្ជូនបក្សី និង ផលិតផលមានដើមកំណើតពីបក្សី ដោយប្រើយានជំនិះកខ្វក់ ដែលអាចយកមេរោគពីកន្លែងមួយ ទៅកន្លែងមួយទៀត



ការគ្មានអនាម័យ ក្នុងបរិវេណជុំវិញ ជាការបន្តជីវិតរបស់វីរុស



ការប្រមូលបក្សីពីប្រភពមិនស្គាល់ តាមកន្លែងផ្សេងៗគ្នា




ការដាក់សត្វផ្សេងគ្នា អោយនៅលាយឡំគ្នា




ការដាក់បក្សីប្រភេទផ្សេងគ្នា អោយនៅលាយឡំគ្នា



ការចិញ្ចឹមបក្សីពាសវាសពាសកាល តាមបឹង ឬ តាមវាល



បក្សីហើរដោយសេរី អាចជាភ្នាក់ងារចំលងវីរុស



ការចិញ្ចឹមបក្សី តាមវាល/តាមស្ទឹង



ការសំលាប់បក្សី ដែលគ្មានអនាម័យត្រឹមត្រូវ



ការចោលបក្សីងាប់មិនបានត្រឹមត្រូវ គឺជាប្រភពដ៏ល្អ
មួយរបស់ជំងឺ

ទិន្នន័យនៃការស្រាវជ្រាវ ក៏បង្ហាញផងដែរអំពីលទ្ធភាព ដែលវីរុសផ្តាសាយបក្សី អាចឆ្លងពីបក្សី ទៅកាន់មនុស្ស ដែលអាចធ្វើអោយស្លាប់បាន ។ ការចំលងបែបនេះ គឺតាមរយៈ:

- ការរស់នៅកៀកជាមួយនឹងបក្សីដែលឈឺ និង ដែលផ្ទុកជំងឺ
- ការប៉ះពាល់ដោយផ្ទាល់ជាមួយនឹងបក្សីដែលផ្ទុកជំងឺ ឬ បក្សីងាប់
- មិនលាងដៃអោយបានស្អាតល្អ ជាមួយសាប៊ូ និង ទឹក បន្ទាប់ពីប៉ះពាល់បក្សី ឬ ផលិតផលដើមកំណើតពីបក្សីរួច
- បរិភោគសាច់ ដែលចំអិនមិនបានឆ្អិនល្អ និង ហុតឈាមបក្សី




កុំចិញ្ចឹមបក្សី នៅក្រោមផ្ទះ




ការសំលាប់គ្មានអនាម័យត្រឹមត្រូវ អាចចំលងជំងឺមកកាន់មនុស្ស (រូបភាពទាំង ២)

## III. ដូច្នេះ តើខ្ញុំត្រូវការជីវសុវត្ថិភាពក្នុងកំរិតណា?

កម្មវិធីជីវសុវត្ថិភាព គួររៀបចំឡើង តាមបែបផែនមួយ ដែលមនុស្សអាចធ្វើតាមបាន។ កម្មវិធីនេះ មិនមែនល្អតែលើក្រដាសនោះទេ។ កម្មវិធីនេះ ចាំបាច់ត្រូវអនុវត្តតាមដោយគ្រប់គ្នា (គ្មានការលើកលែង) ជារៀងរាល់ថ្ងៃ។ កម្មវិធីនេះ ចាំបាច់ត្រូវងាយស្រួលអនុវត្ត និង រៀបចំឡើង ដោយប្រើប្រាស់ពាក្យពេចន៍សាមញ្ញៗ។ លើសពីនេះទៅទៀត កម្មវិធីនេះគួរមានលក្ខណៈសន្សំសំចៃចំណាយអស់តិច ដើម្បីអោយមនុស្សអាចមានលទ្ធភាពអនុវត្តតាមបាន។

ខាងក្រោមនេះ គឺជាជំហានមួយចំនួន ដែលងាយស្រួលយល់ និង ងាយអនុវត្តតាមបាន និង អាចអនុវត្ត ដោយប្រើការយល់ដឹងធម្មតាៗ:

**ក. ការដាក់អោយដោយឡែក - ការពារបក្សីរបស់អ្នក**

ក. ទិញបក្សីដែលមានសុខភាពល្អ រក្សាបក្សីអោយមានសុខភាពល្អ: បក្សីដែលទិញមកថ្មី គួរដាក់អោយដោយឡែក នៅក្នុងទ្រុង អោយបានយ៉ាងហោចណាស់ ១៤ ថ្ងៃ មុនដាក់វាអោយនៅលាយឡំជាមួយ បក្សីដែលមានស្រាប់ នៅក្នុងកសិដ្ឋាន ដើម្បីធានាអោយបានច្បាស់ថា បក្សីដែលទើបមកថ្មីនេះ មិនមានផ្ទុកជំងឺ។ អ្នកអាចប្រើទ្រុងអង្រុត ឬ ទ្រុងដោយឡែក។ ប្រសិនបើបក្សីទាំងនេះមានផ្ទុកជំងឺ វានឹងបង្ហាញរោគសញ្ញានៅក្នុងរយៈពេល ២ សប្តាហ៍។ អ្នកភូមិគួរដឹងថា ជាការសំខាន់ដែលត្រូវដាក់បក្សីប្រភេទផ្សេងគ្នា អោយនៅដោយឡែកពីគ្នា និង មិនត្រូវដាក់ទាអោយនៅលាយឡំជាមួយមាន់ មាន់ ជាមួយជ្រូក និង ទាជាមួយជ្រូកឡើយ។ បក្សីខ្លះមិនបង្ហាញរោគសញ្ញាជំងឺឡើយ ប៉ុន្តែ គឺជាភ្នាក់ងារចំលងជំងឺ។ ផ្តល់ចំណី និង ទឹកស្អាតអោយបក្សីរបស់អ្នក។

ខ. សង់ទ្រុងបក្សី អោយឆ្ងាយពីកន្លែងរស់នៅរបស់គ្រួសារ។ ធ្វើយ៉ាងដូច្នេះ គឺដើម្បីកុំអោយសមាជិកគ្រួសារប៉ះពាល់ជាមួយនឹងកាកសំណល់ លាមក និង រោមរបស់បក្សី។

គ. សង់របងជុំវិញកន្លែងដាក់បក្សី ដោយជ្រើសរើសសំភារៈ ដែលមាននៅក្នុងភូមិ ដូចជា ធាងត្នោត មែកឈើតូចៗ ឬស្សី ។ល។ ធ្វើយ៉ាងណាកុំអោយឆ្កែ ឆ្មា និង បក្សីដទៃទៀត អាចចូលបាន។ របងនេះ ក៏នឹងការពារមិនអោយសត្វដទៃទៀត ដែលអាចផ្ទុកជំងឺ មកប៉ះពាល់ជាមួយបក្សីរបស់អ្នក ផងដែរ។

ឃ. សំអាតរុក្ខជាតិតូចៗ នៅជុំវិញទ្រុងបក្សី ដើម្បីកុំអោយមានជំរក និង អាហារ សំរាប់សត្វ ដែលផ្ទុកជំងឺ។

ង. យកសំរាមទៅចោលជាទៀងទាត់ ដើម្បីលុបបំបាត់ជំរករបស់សត្វចង្រៃទាំងនេះ។

ច. ប្រសិនបើអ្នកប្រទះឃើញបក្សីព្រៃងាប់ ត្រូវចាត់ទុកថាវាផ្ទុកជំងឺដែលមានកំរិតចំលងខ្ពស់។ ប្រើប្រាស់ស្រោមដៃ ដើម្បីចាប់យកវា ទៅកប់ ឬ ដុតចោល។

ឆ. ចៀសវាងចែកសំភារៈ និង ឧបករណ៍ ដែលអ្នកប្រើជាមួយបក្សីរបស់អ្នក ជាមួយនឹងអ្នកជិតខាងរបស់អ្នក។

ជ. បង្ការមិនអោយមានការដក់ទឹកច្រើន។ វាជាការទាក់ទាញ បក្សីទឹក និង បក្សីព្រៃពនាចរ។ ក្នុងពេលជាមួយគ្នា កាត់បន្ថយប្រភពចំណី សំរាប់បក្សីទាំងនេះ។



កន្លែងប្រជល់មាន់



ធ្វើរបងជុំវិញកន្លែងដាក់បក្សី



ដាក់បក្សីថ្មី អោយនៅដោយឡែកពីបក្សីចាស់ អោយបានយ៉ាងហោចណាស់រយៈពេល ១៤ ថ្ងៃ

**ខ. ការត្រួតពិនិត្យចរាចរណ៍ - ចរាចរណ៍ នៅក្នុងកសិដ្ឋាន និង នៅខាងក្រៅកសិដ្ឋាន។ ការកំហិតការចេញចូល មានន័យថាជាការមិនអោយមានការនាំជំងឺចូល។**

ក. ចៀសវាងទៅកន្លែងប្រជល់មាន់ ព្រោះអ្នកអាចនាំវីរុស មកកាន់ទីធ្លាផ្ទះរបស់អ្នក។

ខ. កុំនាំបក្សី ដែលលក់សល់ពីផ្សារត្រលប់មកផ្ទះវិញ ព្រោះបក្សីទាំងនេះបានប៉ះពាល់ជាមួយនឹងបក្សីដទៃទៀត ដែលប្រហែលជាមានជំងឺ។

គ. កុំអោយឈ្មួញកណ្តាល ចូលមកទិញលក់ នៅក្នុងទីធ្លារបស់អ្នក។

ឃ. អ្នកជិតខាង មិត្តភ័ក្រ្ត ឬ ភ្ញៀវផ្សេងទៀត គួរនៅឆ្ងាយពីបក្សីរបស់អ្នក។ កុំទៅមើលបក្សី របស់អ្នកជិតខាងអ្នក។

៦. កុំអនុញ្ញាតអោយយានជំនិះគ្រប់ប្រភេទ ចូលមកក្នុងកន្លែងដាក់បក្សីរបស់អ្នក ។

៧. ប្រសិនបើអ្នកសង្ស័យពីជំងឺផ្តាសាយបក្សី សូមធ្វើជាអ្នកជិតខាងដ៏ល្អម្នាក់ ហើយ រាយការណ៍ទៅកាន់ភ្នាក់ងារសុខភាពសត្វភូមិ ឬ មេភូមិ ឬ ទូរស័ព្ទមកលេខទូរស័ព្ទព័ត៌មានទាន់ហេតុការណ៍ ។



អ្នកទិញលក់បក្សី គួរទិញលក់ នៅតាមដងផ្លូវ




មនុស្សមិនគួរចូលទៅកាន់កសិដ្ឋានដទៃទៀតឡើយ

**គ. អនាម័យ - ភាពស្អាត របស់សំភារៈ និង មនុស្ស ។ សំអាតទីកន្លែង មានន័យថា បក្សីមានសុខភាពល្អ ។**

១. លាងដៃជាមួយសាប៊ូ និង ទឹក បន្ទាប់ពីប៉ះពាល់បក្សី និង ផលិតផលដើមកំណើតពីបក្សីរួច ។ លាងដៃជាមួយសាប៊ូ និង ទឹក អាចសំអាតបាក់តេរី និង វីរុសបាន ពី ៩០ ទៅ ៩៥% ។

២. សំអាតផ្ទះ និង បរិវេណជុំវិញ អោយបានទៀងទាត់ ដោយបោសសំអាត និង ចូកសំរាមចោល ។

៣. សំអាតមេរោគក្នុង និង ជុំវិញទ្រុងបក្សី ។ ត្រូវចងចាំថា ត្រូវសំអាតកំទិចកំទិចេញសិន សំអាតស្ងួត និង បន្ទាប់មកលាងសំអាតសិន មុនពេលដែលអ្នកសំលាប់មេរោគ ។ ថ្នាំសំលាប់មេរោគ នឹងមិនមានប្រសិទ្ធភាព នៅលើផ្ទៃដែលកខ្វក់ឡើយ ។ កុំភ្លេចសំអាត និង សំលាប់មេរោគលើឧបករណ៍ប្រើប្រាស់ទាំងអស់ (ច្បូកចំណី ប៉ែល អំបោស) ។ អ្នកអាចប្រើប្រាស់ TH 4 ឬ កំបោរ ដើម្បីសំលាប់មេរោគលើដី និង នៅក្នុងទ្រុងបក្សី ។ ត្រូវពិនិត្យស្លាកសំគាល់ ឬ សាកសួរភ្នាក់ងារសុខភាពសត្វភូមិរបស់អ្នក អំពីរបៀបលាយសូលុយស្យុង ។

៤. ដុត ឬ កប់បក្សីងាប់ និង ផលិតផលដើមកំណើតពីបក្សី ។ កប់បក្សីងាប់ និង ផលិតផលដើមកំណើតពីបក្សីអោយបានយ៉ាងហោចណាស់ជំរៅ ១ ម៉ែត្រ ។ ចាក់ដីគ្របសត្វងាប់ និង បន្ទាប់មក រោយកំបោរពីលើ និង ចុងក្រោយ ដាក់ដីបន្ថែមទៀត ដើម្បីធានាកុំអោយសត្វដែលដើរស៊ីពាសវាលពាសកាល អាចកកាយចេញបាន ។

៥. យកសំរាម (កាកសំណល់អាហារ ដបប្លាស្ទិក ដប កំប៉ុង ឬ ធុង) ចេញអោយអស់ពីកន្លែងដាក់បក្សី ។

៦. សត្វកណ្តុរ សត្វល្អិត និង សត្វចង្រៃដទៃទៀត អាចកុំអោយចូលមកក្នុងកសិដ្ឋាន ដោយរក្សាកសិដ្ឋានមិនអោយមានសំរាម ។

ធ្វើការពិគ្រោះយោបល់ ជាមួយមន្ត្រីបសុពេទ្យរបស់អ្នក ប្រសិនបើអ្នកសង្ស័យថាបក្សីរបស់អ្នកមានជំងឺ។ កុំរង់ចាំទាល់តែស្ថានភាពចេះតែដុនដាបទៅ។ ការរកឃើញជំងឺបានឆាប់ និង ការរាយការណ៍ភ្លាមៗ ប្រហែលជាអាចជួយបញ្ឈប់ការរាលដាលរបស់ជំងឺបាន។ រោគសញ្ញា ដែលត្រូវប្រុងប្រយ័ត្ន រួមមាន ងាប់ភ្លាមៗ អស់កំលាំង មិនសូវស៊ីចំណី រាគ ពិបាកដកដង្ហើម ដូចជា ក្អក កណ្តាស់ និង ដង្ហក់ ញ័រប្រែបសសៃប្រសាទ សំយ៉ុងស្លាបចុះ ឬ ខ្វិន និង ហើមក្បាល ដោយសិរ ណង់ និង ជើងមានស្នាមជាំ។ កុំប្រើប្រាស់ការព្យាបាល ដែលគ្មានការណែនាំពីមន្ត្រី បសុពេទ្យ ព្រោះអាចមានផលប៉ះពាល់អវិជ្ជមាន ធ្វើអោយបក្សីរបស់អ្នក កាន់តែឈឺធ្ងន់។



លាងដៃជាមួយសាប៊ូ និង ទឹក ក្រោយពេលប៉ះពាល់បក្សីហើយ



សំអាត និង សំលាប់មេរោគ ឧបករណ៍ប្រើប្រាស់ បន្ទាប់ពីប្រើហើយ



សំអាតបរិវេណជុំវិញអោយបានទៀងទាត់



សំលាប់មេរោគលើទ្រុងបក្សី និង ទីធ្លាជុំវិញ



ដុត ឬ កប់បក្សីងាប់ អោយបានត្រឹមត្រូវ

## IV. ឈ្មួញកណ្ដាល និងអ្នកលក់បក្សីរស់ក្នុងផ្សារ

ឈ្មួញកណ្ដាល គឺជាអ្នកយកបក្សីពីភូមិ ទៅផ្សារ។ ពួកគេអាចជាប្រភពចំលងមេរោគទីមួយ ព្រោះពួកគេធ្វើដំណើរពីកន្លែងមួយ ទៅកន្លែងមួយទៀត។ ប្រសិនបើពួកគេមិនធ្វើតាមវិធានការជីវសុវត្ថិភាពទេ ពួកគេអាចចំលងអតិសុខុម-ប្រាណ ដែលអាចបង្កអោយមានជំងឺបក្សីធ្ងន់ធ្ងរមួយទៀត។

**១. ឈ្មួញកណ្ដាល**

ក. កុំដាក់បក្សីច្រើនពេក នៅក្នុងទ្រុងមួយ (៣០០ សង់ទីម៉ែត្រការ៉េ ក្នុងមួយគីឡូក្រាមបក្សី)

ខ. កុំទិញបក្សីឈឺ ឬ ងាប់

គ. លាងដៃជាមួយសាប៊ូ និង ទឹក បន្ទាប់ពីប៉ះពាល់បក្សីហើយ

ឃ. បើអាច ត្រូវមានកន្លែងដោយឡែកសំរាប់ដាក់បក្សីចុះពីយានជំនិះ

ង. កុំដាក់ទ្រុងគរពីលើគ្នា ប្រើប្រាស់ថាស ឬ ក្រដាសសំរាប់ត្រង់កាកសំណល់

ច. កុំដឹកមនុស្ស និង បក្សី ជាមួយគ្នា

ឆ. សំអាតទ្រុង និង យានជំនិះ ជាមួយសាប៊ូ និង ទឹក បន្ទាប់ពីដាក់បក្សីចុះ និង មុនពេលយកមកប្រើប្រាស់ម្ដងទៀត

ជ. កុំទិញ ឬ ដឹកបក្សី ពី និង នៅក្នុងតំបន់ ដែលមានផ្ទុះជំងឺ

ឈ. បោកសំអាតសំលៀកបំពាក់ និង ស្បែកជើង អោយបានយ៉ាងហោចណាស់ម្ដង ក្នុងមួយថ្ងៃ

ញ. ពាក់ម៉ាស ស្រោមដៃ និង ស្បែកជើង នៅពេលប៉ះពាល់ជាមួយនឹងបក្សី




បាញ់ថ្នាំសំលាប់មេរោគ លើយានជំនិះ បន្ទាប់ពីដាក់បក្សីចុះរួច



លាងម៉ូតូ ជាមួយសាប៊ូ និង ទឹក

## ២. ទីផ្សារលក់បក្សីរស់ និង អ្នកលក់បក្សីរស់នៅក្នុងផ្សារ

មានផ្សារលក់បក្សីរស់ នៅទូទាំងប្រទេសកម្ពុជា។ បក្សីរស់ ក៏មាននៅតាមទីសត្តឃាដតូចៗផងដែរ។ ផ្សារលក់ បក្សី គឺជាកន្លែងដែលមមាញឹក ពោរពេញទៅដោយសកម្មភាពរបស់ឈ្មួញកណ្តាល អ្នកលក់ផ្ទាល់ និង អតិថិជន ប្រមូលផ្តុំគ្នា។ ប៉ុន្តែ វាក៏ជាកន្លែងប្រមូលផ្តុំបាក់តេរី វីរុស និង អតិសុខុមប្រាណចំលងរោគដទៃទៀតផងដែរ ដែលអាចឆ្លងរាលដាលយ៉ាងងាយស្រួល និង យ៉ាងឆាប់រហ័ស តាមរយៈសកម្មភាពជាប្រពៃណី នៅក្នុងផ្សារ ដូចជា ការលក់ និង ការទិញបក្សីរស់ ការសំលាប់បក្សី និង ការដាក់បក្សីច្រើនប្រភេទ លាយឡំជាមួយនឹងទំនិញផ្សេងទៀត នៅកន្លែងតែមួយ។ វីរុសផ្តាសាយបក្សី អាចមាននៅតាមផ្សារទាំងនេះ ប្រសិនបើផ្សារទាំងនេះទទួលបក្សីដែល

មានផ្ទុកជំងឺ ឬ ដែលបានប៉ះពាល់ជាមួយនឹងទ្រុង និង យានជំនិះ ដែលមានជាប់មេរោគ។ នៅពេលដែលមានវីរុសនៅក្នុងផ្សារ ការចល័តទីរបស់សំភារៈដែលមានជាប់មេរោគទាំងនេះចេញពីផ្សារ អាចធ្វើអោយវីរុសនេះ ឆ្លងរាលដាលទៅទីកន្លែង និង ផ្សារដទៃទៀត។ ការអនុវត្តអនាម័យមិនបានល្អ ក៏ធ្វើអោយស្ថានភាពកាន់តែអាក្រក់ផង ដែរ។ ដើម្បីបង្ការមិនអោយមានការឆ្លងរាលដាលជំងឺឆ្លង អ្នកលក់ដូរត្រូវអនុវត្តអនាម័យល្អ ដោយធានាថា សាច់របស់សត្វត្រូវបានកែច្នៃ និង ធ្វើបានត្រឹមត្រូវ ហើយ អតិថិជនដឹងអំពីរបៀបរៀបចំសាច់ នៅពេលដែលពួកគេត្រលប់មកផ្ទះវិញ។

អ្នកលក់ដូរ និង អ្នកគ្រប់គ្រងផ្សារ គួរធ្វើទៅតាមវិធានការខាងក្រោមនេះ:

- ✓ មានទ្រុងដែលងាយស្រួលចំណាំ ដើម្បីអោយអ្នកលក់ម្នាក់ៗដឹងថាទ្រុងណាមួយ ជាទ្រុងរបស់ពួក គេ។
- ✓ មានទ្រុងសំរាប់ដាក់បក្សីឈឺ និង/ឬ ងាប់ និង កត់ត្រាអំពីបក្សីឈឺ និង ងាប់។
- ✓ សំអាតទ្រុង កន្លែងលក់ និង ឧបករណ៍ដទៃទៀត អោយបានរៀងរាល់ថ្ងៃ យ៉ាងហោចណាស់ជាមួយសាប៊ូ និង ទឹក។
- ✓ សំអាត និង សំលាប់មេរោគកន្លែងលក់ អោយបានយ៉ាងហោចណាស់ម្តងក្នុងមួយសប្តាហ៍។ គួរបិទផ្សារមួយខែម្តង ដើម្បីសំអាត និង សំលាប់មេរោគអោយបានសព្វ។
- ✓ បើអាច មានកន្លែងចូល និង ចេញតែមួយ។ ធ្វើបែបនេះនឹងធ្វើអោយលំហូរចរាចរណ៍របស់មនុស្សកាន់តែរលូន។
- ✓ សំអាតជញ្ជីង និង កំរាលអោយអស់លាមក រោម និង កំទិចកំទីដទៃទៀត។
- ✓ ដាក់ផ្សារលក់បក្សីរស់អោយនៅដោយឡែក និង មានកន្លែងលក់អោយបានសមស្រប។ កន្លែងលក់ នេះគួរនៅអោយឆ្ងាយពីកន្លែងលក់ រៀបចំ ឬ ចំអិនម្ហូបអាហារ។
- ✓ លក់តែបក្សីមួយប្រភេទ នៅមួយកន្លែងៗ។ បើមិនអាចធ្វើបានទេ យ៉ាងហោចណាស់ត្រូវប្រើប្រាស់ទ្រុងដោយឡែកពីគ្នា។
- ✓ ដាក់កន្លែងសំលាប់បក្សី អោយនៅដោយឡែកពីកន្លែងលក់បក្សីរស់។
- ✓ អនុវត្តអនាម័យល្អមុនពេល ក្នុងពេល និង ក្រោយពេលសំលាប់បក្សីរួច។
- ✓ ផ្សារ គួរមានកម្មវិធីត្រួតពិនិត្យកណ្តុរ និង សត្វល្អិតចង្រៃ (ដូចជា រុយ ជាដើម)។ មិនគួរអនុញ្ញាតអោយឆ្កែ និង ឆ្មារ ចូលក្នុងផ្សារឡើយ។



ការដាក់លក់មិនបានត្រឹមត្រូវ - ដាក់ម្ហូបឆៅ និង ឆ្អិន ជាមួយគ្នា



សំអាតកន្លែងលក់ និង ជញ្ជីងអោយបានស្អាត

សំអាត និង សំលាប់មេរោគ នៅចុងថ្ងៃនីមួយៗ។ កុំភ្លេចកន្លែងលក់ និង ទ្រុង។ សំអាតលាមក និង រោមទាំងអស់ ជាមួយនឹងទឹក ហើយ បន្ទាប់មក បាញ់ថ្នាំសំលាប់សត្វល្អិតដែលសមស្រប (ដូចជា TH 4, GPC8, First Stop, កំបោរ) ។





សំលាប់បក្សី នៅក្នុងផ្សារ ដោយគ្មានអនាម័យត្រឹមត្រូវ

កន្លែងលក់មិនសមស្រប

សារដែលត្រូវចងចាំ -

កម្មវិធីជីវសុវត្ថិភាព គឺមានសារៈសំខាន់ណាស់ ដើម្បីចិញ្ចឹមបក្សីអោយមានសុខភាពល្អ។ បក្សីនឹងមានបញ្ហាសុខភាពតិចតួចបំផុត និង លូតលាស់ធំធាត់ជាងមុន ផលិតស៊ុតបានច្រើនជាងមុន ហើយអ្នកផលិតនឹងរកលុយបានច្រើនជាងមុន។ នៅពេលដែលកសិករ អ្នកលក់ដូរ ឈ្មួញកណ្តាល អ្នកលក់បក្សីរស់ក្នុងផ្សារ អនុវត្តជីវសុវត្ថិភាព ការគំរាមកំហែងរបស់ជំងឺនានា ដូចជា ជំងឺផ្តាសាយបក្សី ជាដើម នឹងត្រូវបានកាត់បន្ថយ។ កម្មវិធីនេះ គួររៀបចំឡើង ដើម្បីអោយគ្រប់គ្នាអាចយល់បាន និង មិនមានបញ្ហា ក្នុងការធ្វើតាមជំហាននានា។ សូមប្រាប់មិត្តភ័ក្រ្ត និង អ្នកជិតខាងរបស់អ្នកថា បក្សីដែលមានសុខភាពល្អ មានប្រភពពីកសិដ្ឋាន ដែលអនុវត្តតាមវិធានការជីវសុវត្ថិភាព។

ប្រសិនបើអ្នកមានបក្សីងាប់ ហើយ/ឬ អ្នកសង្ស័យថា ជាជំងឺផ្តាសាយបក្សី សូមជូនដំណឹងទៅកាន់ភ្នាក់ងារសុខភាពសត្វភូមិ មេភូមិ ឬ ប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាលស្រុក ឬ ខេត្តក៏មានលេខទូរស័ព្ទព័ត៌មានទាន់ហេតុការណ៍ ដែលអ្នកអាចហៅទៅបាន និង រាយការណ៍អំពីបញ្ហាបែបនេះ។ លេខ ទូរស័ព្ទរួមមានៈ

០១២-៨៣៣-៧៩៥

០១២-២១៤-៩៧០

## ឧបសម្ព័ន្ធទី ១

**ពិធីសារសំរាប់ការសំអាត និង ការសំលាប់មេរោគ**

ជានិច្ចជាកាល សត្វតែងតែប្រឈមនឹងអតិសុខុមប្រាណ ហើយ អតិសុខុមប្រាណមួយចំនួនអាចបង្កអោយមានជំងឺ។ អតិសុខុមប្រាណទាំងនេះ អាចបន្តជីវិតរបស់វា ពីហ្វូងសត្វមួយ ទៅហ្វូងសត្វមួយទៀត ព្រោះវាទទួលបានការការពារ ដោយធូលី (សារធាតុសរីរាង្គ) ឬ ជីវសរីរៈ ដែលមាននៅក្នុងបរិស្ថាន។ ដើម្បីការពារមិនអោយមាន ជំងឺកើតឡើង យើងត្រូវជួយ**កាត់ផ្តាច់តំណភ្ជាប់នេះ!**

ការសំអាត និង ការសំលាប់មេរោគ (C&D) គឺជាផ្នែកសំខាន់ពីរ នៃកម្មវិធីជីវសុវត្ថិភាពទាំងមូល និង គឺជា ឧបករណ៍ល្អបំផុត ប្រើប្រាស់សំរាប់កាត់ផ្តាចតំណភ្ជាប់របស់ជំងឺ។ ជានិច្ចជាកាល ត្រូវដាក់បញ្ចូលផែនការអនាម័យ ដែលគ្រប់ជ្រុងជ្រោយ និង ដែលសំរបទៅតាមស្ថានភាពជាក់ស្តែង នៅក្នុងកម្មវិធីសុខភាពនានា សំរាប់គ្រប់កន្លែងទាំងអស់។ កម្មវិធីដែលល្អ អាចទទួលបរាជ័យ ប្រសិនបើមានការខ្វះចន្លោះកន្លែងណាមួយ។ ការដាក់អោយនៅដោយឡែក និង ការធ្វើអោយលែងមានមេរោគ គឺជាគោលដៅចុងក្រោយ ប៉ុន្តែ មិនមានលក្ខណៈប្រាកដនិយម។ ដូច្នេះ ត្រូវបង្កើតអោយមានគោលបំណងដែលអាចសំរេចទៅបាន ប្រសិនបើចង់រក្សាបាននូវកំរិតអនាម័យថេរ។

**គោលដៅអនាម័យ:**

១. សំអាតអោយបានទាំងស្រុងតាមកន្លែងមានសត្វទាំងអស់ - មិនគួរមានការលើកលែង តាមកន្លែងដែលត្រូវបានដាក់បញ្ចូល នៅក្នុងកម្មវិធីឡើយ។

២. សំអាតអោយសព្វកន្លែង - មិនត្រូវមានធូលី ដែលអាចមើលឃើញនឹងភ្នែកឡើយ។

៣. កាត់បន្ថយអតិសុខុមប្រាណ អោយនៅត្រឹមកំរិតទាបបំផុត ដែលអាចធ្វើទៅបាន (ជិតសូន្យ) តាមរយៈ ការសំលាប់មេរោគ អោយបានត្រឹមត្រូវ។

៤. យកបក្សីពីប្រភពដែលស្គាល់ - ធានាថា បក្សីទាំងនេះមិនមកដល់កន្លែងរបស់អ្នក ដោយផ្ទុកនូវមេរោគ នានា ដូចជា វីរុសដង្កោរែក ឬ អតិសុខុមប្រាណដែលបង្កជំងឺរាគ ឡើយ។

**ការត្រៀមរៀបចំសំអាត:**

១. បង្កើតការត្រួតពិនិត្យកណ្តុរ និង សត្វល្អិតចង្រៃ

២. ល្អបំផុត ត្រូវសំអាត នៅពេលលែងមានបក្សី

៣. ជំរះស្មៅជុំវិញចេញ

៤. យកសំភារៈនានា និង ឧបករណ៍ដទៃទៀត ដែលមិនអាចសំអាត និង សំលាប់មេរោគ នៅក្នុងកន្លែងដាក់ បក្សីចេញ ដូចជា ចង្ក្រានកំដៅ ប្រដាប់ដាក់ទឹក និង ប្រដាប់ដាក់ចំណី។

៥. យកចំណីដែលនៅសល់ ពីធុងចំណី និង ប្រដាប់ដាក់ចំណីចេញ។

៦. យកសំរាម/កំរាល ចេញពីកន្លែងដាក់ចំណី ហើយ យកវាទៅអោយឆ្ងាយ តាមដែលអាចធ្វើបាន។

**របៀបសំអាតៈ**

មិនអាចសំលាប់មេរោគក្នុងធូលីបានឡើយ!

គោលបំណងនៃការសំអាត គឺដើម្បីសំអាតកំទិចកំទី ធូលី ដី លាមក និង សារធាតុសរីរាង្គ ដែលអាចមើលឃើញ នឹងភ្នែកចេញទាំងអស់។ សំអាតអោយបានសត្វ ដោយប្រើកំលាំងអោយបានច្រើន ដើម្បីសំអាតភាពកខ្វក់ចេញ។ បោសសំអាតធូលី សំបុកពីងពាង និង រោមបក្សី តាមជញ្ជាំង សំបុក ទ្រុង ធ្នឹម ផ្ដោងដំបូល កង្ហារ និង កន្លែងដែល អាចបោសដល់ផ្សេងទៀត នៅខាងក្នុង និង ខាងក្រៅកន្លែងដាក់បក្សី។ កុំភ្លេចបន្ទប់សេវា។

ដុសកំណកកំទិចកំទី និង យកចិត្តទុកដាក់ចំពោះកន្លែងដែលពិបាកបោសដល់។ លាងសំអាតផ្ទៃទាំងអស់ ជាមួយ ទឹក និង ម៉្សៅសាប៊ូ។ ម៉្សៅសាប៊ូ ឬ សារធាតុសំអាត ជួយកាត់បន្ថយភាពស្អិតនៅលើផ្ទៃ (ធ្វើអោយទឹក "កាន់តែសើម") បំបែកកំទិចធូលី ធ្វើអោយប្រេងនិងខ្លាញ់រលាយ ធ្វើអោយកំទិចធូលីអណ្តែត ធ្វើអោយរលាយអំបិល និង លាងផ្ទៃ អោយជ្រះធូលី។ មានម៉្សៅសាប៊ូ ២ ប្រភេទ ដែលអាចយកមកប្រើប្រាស់បានៈ ក) ម៉្សៅសាប៊ូអាល់កាឡាំង ដែល សំអាតជាតិប្រូតេអ៊ីន និង ខ្លាញ់ និង ខ) ម៉្សៅសាប៊ូអាស៊ីដ ដែលសំអាតកំណករ៉ែ។ ការសំអាតបានសព្វល្អ (ប្រើប្រាស់ ម៉ាស៊ីនសំអាតដែលមានសំពាធខ្ពស់) ការប្រើម៉្សៅសាប៊ូ និង ទុកផ្អាប់យូរ (ការប្រើសំពាធទាប/ ហ្វូម/ជែល) និង ប្រើប្រាស់ទឹកក្តៅ ឬ ត្រជាក់ សុទ្ធតែរួមចំណែកបង្កើនប្រសិទ្ធភាពនៃការលាងសំអាត។

| |
|---|
| ការលាងសំអាតដែលស្អាតល្អ នឹងសំអាតអតិសុខុមប្រាណបានពី ៨០ ទៅ ៩០% នៅលើផ្ទៃ ដោយប្រើប្រាស់ទឹក និង ម៉្សៅសាប៊ូ។ ការសិក្សាបានបង្ហាញថា ការផ្លុំធូលីអាចកាត់បន្ថយអតិសុខុមប្រាណបាន ៣% ការបាញ់ខ្យល់បាន ៣១% ការលាងជាមួយទឹកបាន ៧៥% និង ការលាងជាមួយម៉្សៅសាប៊ូបានពី ៨០ ទៅ ៩០%។ |

របៀបសំលាប់មេរោគៈ

ការសំអាតបានល្អ គួរធានាបានថា ថ្នាំសំលាប់មេរោគ អាចចូលទៅដល់អតិសុខុមប្រាណ ដែលនៅសល់លើផ្ទៃ និង កាត់បន្ថយវាបានយ៉ាងហោចណាស់ ៩៩%។ ជ្រើសរើសថ្នាំសំលាប់មេរោគ និង ប្រើប្រាស់វា ទៅតាមកន្លែង និង ឧបករណ៍ដែលអ្នកមាន។ ឈ្មោះផលិតផលផ្សេងៗគ្នា និង លក្ខណៈរបស់វា នឹងបង្ហាញ នៅក្នុងអត្ថបទដោយឡែក។

គេអាចប្រើថ្នាំសំលាប់មេរោគ ដោយសំពាធទាប (ទុយោប្រើក្នុងសួនច្បារ) ហ្វូម ដោយប្រើបំពង់បាញ់ ហ្វូម ឬ ដោយបំពង់បាញ់កំដៅ ។ អ្នកខ្លះបាញ់សារធាតុហ្វ័រម៉ាល់ ។ ប្រសិនបើធ្វើដូច្នេះ កំដៅបន្ទប់អោយមានកំដៅលើសពី ២០ អង្សាសេ ។ បើមិនដូច្នោះទេ ប្រើប្រាស់ថ្នាំសំលាប់មេរោគ ដែលមានប្រសិទ្ធភាពក្នុងសីតុណ្ហភាពត្រជាក់ ។

ជំហាននៃការសំលាប់មេរោគអោយបានត្រឹមត្រូវៈ

១. ជាការសំខាន់ត្រូវប្រើប្រាស់ថ្នាំសំលាប់មេរោគ លើផ្ទៃស្ងួត ។ ដូច្នេះ បឺតខ្យល់ចេញពីកន្លែងដាក់បក្សី ក្រោយពេលសំអាតហើយ ។

២. គណនារកក្រឡាផ្ទៃ ដែលត្រូវសំលាប់មេរោគ ដោយប្រើរូបមន្តខាងក្រោមៈ

កន្លែងដាក់បក្សី ដែលគ្មានទ្រុងៈ

បណ្តោយ x ទទឹង x ២,៦ = ហ្វីតការ៉េ

កន្លែងដាក់បក្សី ដែលមានទ្រុងៈ

បណ្តោយ x ទទឹង x ៣ = ហ្វីតការ៉េ

៣. រៀបចំលាយសូលុយស្យុងថ្នាំសំលាប់មេរោគ ផ្អែកទៅតាមក្រឡាផ្ទៃសរុប ដែលត្រូវសំលាប់មេរោគ និងប្រើប្រាស់កំរិតថ្នាំ ដែលផ្តល់ដោយអ្នកផលិត ។ ឧទាហរណ៍ៈ

ថ្នាំសំលាប់មេរោគ TH 4

កំរិតប្រើប្រាស់ TH 4១ លីត្រ ក្នុងទឹក ២០០ លីត្រ

ល្បាយសូលុយស្យុង ៣០០ មីលីលីត្រ ប្រើសំរាប់ក្រឡាផ្ទៃ ១ ម៉ែត្រការ៉េ ដែលត្រូវសំលាប់ មេរោគ

៤. ចាប់ផ្តើមប្រើពីដំបូលរបស់កន្លែងដាក់បក្សី និង ប្រើចុះមកដល់ផ្ទៃបាត ។

៥. យកសំភារៈ និង ឧបករណ៍ ដែលបានសំលាប់មេរោគរួច ចូលទៅក្នុងកន្លែងដាក់បក្សីវិញ ។

៦. បិទ និង ចាក់សោរកន្លែងដាក់បក្សី ។ ធ្វើអោយមានខ្យល់ចេញចូល យ៉ាងហោចណាស់ក្រោយទុកចោល ៨ ម៉ោង ។

៧. បើអាច ពិនិត្យតាមដានការសំអាត និង ការសំលាប់មេរោគ ដោយប្រមូលវត្ថុវិភាគបរិស្ថាន ដើម្បីរាប់ចំនួនបាក់តេរី ។